**San Diego Unified School District**
EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682

William A. Kowba
អ្នកតំណាងអគ្គស្នងការក្រសួងអប់រំ

ខែ កុម្ភៈ ឆ្នាំ ២០០៨

មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

នៅថ្ងៃ សៅរ៍ ទី ១៩ ខែ មករា គណៈកម្មការក្រសួងអប់រំប្រចាំក្រុងបាបធ្វើការបោះឆ្នោតជាសម្ងាត់ជ្រើសរើសលោកបណ្ឌិត Terry Grier ជាអគ្គស្នងការអប់រំប្រចាំក្រុងរបស់យើង។ក្នុងកំឡុងពេល ពីរ-បីខែ ខាងមុខនេះ ខ្ញុំនឹងឈរជាតំណាងអគ្គស្នងការអប់រំជាបណ្តោះអាសន្នដើម្បីជួយដល់លោក Grier ហើយពេលនេះគាត់កំពុងតែធ្វើការរបស់គាត់នៅរដ្ឋ North Carolina ។

រយះពេលខ្ញុំឈរជាតំណាងលើកិច្ចការនេះ ខ្ញុំមានបំណងចង់ធ្វើការបញ្ជាក់ដើម្បីផ្តល់ការអប់រំដល់សិស្សទាំងអស់អោយបានយ៉ាងល្អប្រពៃពិតប្រាកដ។ ខ្ញុំមានសេចក្តីរីករាយជាទីបំផុតដែលលោកអ្នកជាមាតាបិតាបានជួយដល់កូនចៅសិក្សានៅតាមផ្ទះ ព្រមទាំងដើរតួរដ៏សំខាន់ក្នុងការជួយពង្រឹងដល់សាលារៀនរបស់យើង។

មាតាបិតាសិស្សបានជួយដល់ពង្រឹងការសិក្សាសិស្សនៅតាមសាលារៀនរបស់យើងជារៀងរាល់ថ្ងៃ។ គោលបំណងរបស់យើងគឺធ្វើយ៉ាងណាដើម្បីឲ្យមាតាបិតាមានអារម្មណ៍ទទួលស្វាគមន៍នៅនៅតាមសាលារៀនរបស់យើង។ ចាប់តាំងពីយើងបានបើកម្មវិធី Family Friendly School កាលពីឆ្នាំកន្លងទៅនេះ យើងមានចំនួនមាតាបិតា និងបុគ្គលិកស្នាក់បំរើជួយដល់សាលារៀនជាច្រើន។ យើងមានសាមាជិកស្នាក់បំរើកិច្ចការសាលារៀនជាងមួយលានម៉ោង។ យើងសង្ឃឹមថា លោកអ្នកអាចជួយបង្កើនចំនួនការបំរើនេះអោយបានច្រើនទាឆ្នាំនេះ។

នារយះពេលបួន-ប្រាំឆ្នាំកន្លងទៅនេះ ក្រសួងអប់រំប្រចាំក្រុង San Diego បានពង្រឹងកិច្ចការសំខាន់ៗមួយចំនួន។យើងសាងសងសាលារៀនថ្មីៗ និងជួសជុលសាលារៀនចាស់ៗមួយចំនួន។ យើងបានពង្រឹងការសិក្សារបស់សិស្ស និងកម្មវិធីសិក្សារបស់យើង។ យើងបន្តការរក្សាថវិការសាលារៀនបានមានស្ថេរភាព។ កិច្ចការដ៏មហាអស្ចារ្យទាំងនេះគឺមកពីការប្រឹងប្រែងរបស់លោកគ្រូ-អ្នកគ្រូ, ចាងហ្វាងប្រចាំសាលារៀន, មាតាបិតា, សិស្សានុសិស្ស ព្រមទាំងបុគ្គលិកសាលារៀនប្រចាំក្រុងរបស់យើងផងដែរ។ ខ្ញុំព្យាយាមប្រឹងប្រែងស្តាបនាសាលារៀនរបស់យើងអោយបានជោគជ័យ ហើយយើងត្រូវរួមសហការណ៍គ្នាដើម្បីពង្រឹងសាលារៀនរបស់យើងអោយក្លាយទៅជាសាលារៀនដ៏ល្អប្រសើរនៅក្នុងសហរដ្ឋអាមេរិក។

នារយះពេលខែខាងមុខនេះ ខ្ញុំនឹងអញ្ជើញទៅពិនិត្យមើលសាលារៀនទាំងអស់នៅក្នុងសហគមន៍ San Diego របស់យើង។ ខ្ញុំសង្ឃឹមថានឹងបានជួបប្រជុំប្រស្រ័យជាមួយលោកអ្នកដើម្បីដោះស្រាយអំពី ការសិក្សារបស់កូនលោកអ្នកអោយបានល្អរលាស់។

ដោយក្តីរាក់ទាក់

William A. Kowba
អ្នកតំណាងអគ្គស្នងក្រសួងអប់រំប្រចាំក្រុង

**BECOMING AMERICA'S BEST**

Superintendent for February 2008. Cambodian Version.